# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៨

## កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ( EOD )

---


អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា

មាតិកា........................................................................................................................................២
សេចក្តីផ្តើម...................................................................................................................................៣
ការកំទេចគ្រាប់យុទ្ធភ័ណ្ឌ...................................................................................................................៤
១.ទ្រង់ទ្រាយ......................................................................................................................................៤
២.នីតិវិធីកំទេចគ្រាប់យុទ្ធភ័ណ្ឌ និង កិច្ចប្រតិបត្តិការ...........................................................................៤
២.១ គោលការណ៍ទូទៅ.........................................................................................................................៤
២.២ លក្ខណៈសម្បត្តិ...........................................................................................................................៥
២.៣ នីតិវិធីនៃការដោះបន្សាប និង ធ្វើឲ្យមីន/គ្រាប់មានសុវត្ថិភាព.............................................................៦
២.៤ នីតិវិធីកំទេចគ្រាប់.......................................................................................................................៧
២.៥ ការដឹកជញ្ជូន ការប្រើប្រាស់ និង ការទុកដាក់គ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ...................................៧
៣.ការទទួលខុសត្រូវ និង កាតព្វកិច្ច.....................................................................................................៨
៣.១ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន..................................៨
៣.២ ប្រតិបត្តិករដោះមីន.......................................................................................................................៨

# សេចក្តីផ្តើម

គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមាននិយមន័យច្រើន ប៉ុន្តែក្នុងស្តង់ដានេះសំដៅលើគ្រាប់រំសេវនានា (រួមទាំងគ្រាប់កាំភ្លើងដៃ) ក្រៅពីគ្រាប់មីនដែលបានរួមបញ្ចូលនៅក្នុងគោលដៅបោសសំអាតនៃកម្មវិធីដោះមីន ដែលបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន។ គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អាចត្រូវបានបោសសំអាតជាផ្នែកមួយនៃកិច្ចព្រមព្រៀងបោសសំអាតមីន ឬអង្គការដែលមានឯកទេសខាងកំទេច គ្រាប់យុទ្ធភ័ណ្ឌ (EOD) អាចធ្វើការបោសសំអាតក្រោមការរៀបចំដោយឡែក តាមរយៈការផ្តល់ថវិកាពីម្ចាស់ជំនួយ ឬគំរោងរបស់ក្រុមហ៊ុនពាណិជ្ជកម្ម។ ក្នុងគោលបំណងនៃស្តង់ដានេះ សកម្មភាពទាំងពីរខាងលើត្រូវរួមបញ្ចូលនូវកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ។

គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលបានរកឃើញក្នុងអំឡុងពេលបោសសំអាត ភាគច្រើនជាគ្រាប់មានទំហំតូចដូចជា គ្រាប់បែកដៃ និងគ្រាប់កាំភ្លើងត្បាល់។ គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក៏អាចមានទំហំធំដែរដូចជា គ្រាប់កាំភ្លើងធ្លោង គ្រាប់ទំលាក់ពីយន្តហោះ និងគ្រាប់បែកបណ្តុំ។ ទំហំមានលក្ខណៈផ្សេងៗពីគ្នា និងមានលក្ខណៈស្មុគស្មាញ ដែលទាមទារអោយមានការយកចិត្តទុកដាក់ជាពិសេសចំពោះការគ្រប់គ្រងកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ។

គោលបំណងនៃស្តង់ដានេះគឺផ្តល់នូវការកំណត់ជាក់លាក់ និងការណែនាំសំរាប់ការគ្រប់គ្រងកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះនៅកម្ពុជា។ ស្តង់ដានេះក៏ផ្តល់នូវគោលការណ៍ទូទៅ និងការទទួលខុសត្រូវផ្នែកគ្រប់គ្រងសំរាប់ការកំទេចគ្រឿងផ្ទុះ។ ស្តង់ដានេះមិនបានផ្តល់ការណែនាំបច្ចេកទេសជាក់លាក់សំរាប់ការកំទេចគ្រាប់យុទ្ធភ័ណ្ឌពិសេសណាមួយឡើយ។

# ការកំទេចគ្រឿងផ្ទុះ

## ១.ទ្រង់ទ្រាយ

ស្តង់ដានេះ ផ្តល់ការកំណត់ជាក់លាក់ និងគោលការណ៍ណែនាំសំរាប់សុវត្ថិភាពនៃប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ដែលជាផ្នែកមួយនៃកម្មវិធីដោះមីន។ ស្តង់ដានេះត្រូវបានយកមកអនុវត្តក្នុងការកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក្រៅពីគ្រាប់មីន។ ការកំទេចគ្រាប់មីនមានចែងនៅក្នុងស្តង់ដាផ្សេងទៀត។

## ២.នីតិវិធី និង កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ

### ២.១ គោលការណ៍ទូទៅ

កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ពាក់ព័ន្ធទៅនឹងការរាវរក ការកំណត់អត្តសញ្ញាណគ្រាប់ ការវាយតំលៃនៅការដ្ឋាន ការធ្វើអោយគ្រាប់មានសុវត្ថិភាព ការកាយយកគ្រាប់ និងការកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដោយសុវត្ថិភាព។ កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ អាចជាផ្នែកមួយនៃកិច្ចប្រតិបត្តិការបោសសំអាតប្រចាំថ្ងៃ តាមរយៈការរកឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុង ឬនៅក្បែរតំបន់ចំការមីន ហើយក្នុងករណីនេះត្រូវធ្វើការស្រាវជ្រាវបច្ចេកទេសលំអិត និងរៀបចំជាឯកសារភ្ជាប់ជាមួយឯកសារចំការមីនសំរាប់អ្នកទទួលខុសត្រូវចំការមីនប្រើប្រាស់។ កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ក៏អាចអនុវត្តទៅលើគ្រាប់យុទ្ធភ័ណ្ឌ មិនទាន់ផ្ទុះដែលរកឃើញនៅក្រៅតំបន់ចំការមីនផងដែរ។ កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ អាចពាក់ព័ន្ធនឹងគ្រាប់តែមួយ ឬគ្រាប់ច្រើនដែលរកឃើញនៅកន្លែងជាក់លាក់ណាមួយ ដូចជាទីតាំងកាំភ្លើងត្បាល់ ឬទីតាំងកាំភ្លើងធ្លោងជាដើម។ ប្រតិបត្តិការនេះក៏អាចពាក់ព័ន្ធនឹងគំនរគ្រាប់រំសេវដែលគេបោះបង់ចោលនៅតាមលេណដ្ឋាន ឬនៅតាមចំណុចដែលគេទុកគ្រាប់រំសេវ។

ការគ្រប់គ្រងដោយប្រសិទ្ធភាពលើកម្មវិធីដោះមីន និងគំរោងបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនានារាប់បញ្ចូលទាំងការបង្កើត និងការថែរក្សាសមត្ថភាពក្នុងកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព។ ការគ្រប់គ្រងនេះពាក់ព័ន្ធនឹងការសិក្សាវាយតំលៃជាផ្លូវការពីគ្រោះថ្នាក់នៃការគំរាមពីគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការបង្កើតសមត្ថភាពនៃកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះប្រកបដោយសុវត្ថិភាព និងប្រសិទ្ធ-ភាព។ សមត្ថភាពនេះ រួមមានការរៀបចំនីតិវិធីសមស្របក្នុងការដោះបន្សាប និងការធ្វើឲ្យគ្រាប់មានសុវត្ថិភាព ការប្រើប្រាស់បុគ្គលិកដែលមានការបណ្តុះបណ្តាល និងគុណសម្បត្តិត្រឹមត្រូវ និងអ្នកជំនាញឯកទេសខាងគ្រឿងផ្ទុះព្រមទាំងការប្រើប្រាស់សំភារៈដែលមានប្រសិទ្ធភាព និងសុវត្ថិភាព ការរក្សាទុក និងការផ្គត់ផ្គង់។ បន្ថែមលើចំនុចខាងលើត្រូវមានបទដ្ឋានប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ដែលមានសុវត្ថិភាព និងពេញលេញរបស់ប្រតិបត្តិករដោះមីនថែមទៀត។

ការបង្កើតសមត្ថភាពប្រតិបត្តិការកំទេចគ្រឿងផ្ទុះអោយមានសុវត្ថិភាព និងប្រសិទ្ធភាពតម្រូវអោយមានការបង្កើតលំដាប់កំរិតជំនាញឯកទេសទៅតាមទំហំនៃតម្រូវការប្រតិបត្តិការ។ តាមគោលការណ៍ទូទៅ ប្រតិបត្តិករអាចកំទេចតែគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងស្ថានភាពដែលពួកគេបានហ្វឹកហ្វឺនទទួលស្គាល់ និងមានអាជ្ញាប័ណ្ណផ្លូវការប៉ុណ្ណោះ។ ចំពោះករណីដ៏ទៃទៀត ត្រូវប្រគល់ទៅអ្នកឯកទេសដែលមានកំរិតជំនាញខ្ពស់ជាង។

### ២.២ លក្ខណៈសម្បត្តិ

ការកំទេចគ្រឿងផ្ទុះអាចត្រូវបានអនុវត្តដោយកំរិតឯកទេសផ្សេងៗគ្នា ពីការដោះបន្សាបគ្រាប់ធំៗគ្រាប់មីុស៊ីល រហូតដល់ការកំទេចគ្រាប់បែក និងគ្រាប់រំសេវធុនតូច។ លក្ខណៈវិនិច្ឆ័យនៃអ្នកកំទេចគ្រឿងផ្ទុះ គួរស្របទៅនឹងការគំរាមនៃប្រភេទរបស់គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងគ្រាប់រំសេវដែលជួបប្រទះជាញឹកញាប់។ ដូចនេះលក្ខណៈសម្បត្តិរបស់បុគ្គលិកទាំងអស់ត្រូវបំពេញតាមតម្រូវការ និងបទបញ្ញត្តិនានារបស់អាជ្ញាធរមីន ដូចមានណែនាំខាងក្រោម៖

ក) ការកំទេចគ្រឿងផ្ទុះកំរិត១ :លក្ខណៈសម្បត្តិរបស់អ្នកកំទេចគឺអាចរុករកបង្ហាញប្រាប់បញ្ជាក់អត្តសញ្ញាណនិងកំទេចគ្រាប់ប្រភេទតែមួយនៅនឹងកន្លែងក្រោមការត្រួតពិនិត្យដោយឆ្លងកាត់ការហ្វឹកហ្វឺនពិសេស និងផ្លូវការក្នុងការអនុវត្តភារកិច្ចនោះ។

ខ) ការកំទេចគ្រឿងផ្ទុះកំរិត២: លក្ខណៈសម្បត្តិរបស់អ្នកកំទេចគឺអាចរុករក បញ្ជាក់អត្តសញ្ញាណ រំកិលគ្រាប់ ដឹកជញ្ជូន និងកំទេចគ្រាប់ច្រើនប្រភេទ ដោយឆ្លងកាត់ការហ្វឹកហ្វឺនពិសេស និងផ្លូវការក្នុងការអនុវត្តភារកិច្ច ក្រោមការត្រួតពិនិត្យសមស្រប។

គ) ការកំទេចគ្រឿងផ្ទុះកំរិត៣: លក្ខណៈសម្បត្តិរបស់អ្នកកំទេចគឺបានបណ្តុះបណ្តាលឯកទេសច្បាស់លាស់ក្នុងការអនុវត្តន៍នីតិវិធីដោះបន្សាប និងចុងក្រោយកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ លើកលែងចំនុចឯកទេសនានាដូចមានចែងនៅកំរិត៤ខាងក្រោម ដោយឆ្លងកាត់ការហ្វឹកហ្វឺនពិសេស និងផ្លូវការក្នុងការអនុវត្តភារកិច្ចនោះ។

ឃ) ការកំទេចគ្រឿងផ្ទុះកំរិត៤: សំរាប់បុគ្គលិកឯកទេសកំទេចគ្រឿងផ្ទុះមួយចំនួនតូច ដែលបានបណ្តុះបណ្តាលជាផ្លូវការ និងត្រូវបានទទួលស្គាល់ថាមានលក្ខណៈសម្បត្តិក្នុងការអនុវត្តន៍ការងារ ឯកទេសនានាតាមលក្ខណៈផ្សេងៗដូចខាងក្រោម:

- ការកំទេចអាវុធនាំផ្លូវ
- ការដោះបំបែកគ្រឿងផ្ទុះ
- ការកំទេចគ្រាប់គីមី ជីវសាស្ត្រ វិទ្យុសកម្ម និងអាវុធនុយក្លេអែរ
- ការកំទេចគ្រឿងផ្ទុះច្នៃប្រឌិត
- ការកំទេចអាវុធដែលមានផ្ទុកគ្រោះថ្នាក់ដោយសារប្រេង
- ការកំទេចមានលក្ខណៈធំៗ លើគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលបានដោះបន្សាបរួច ឬ គ្រឿងផ្ទុះនានាដែលកាយរកឃើញ និង
- ការដោះអន្ទាក់ ប្រព័ន្ធកែច្នៃនានា ដែលមិនមែនជាផ្នែកនៃការកែច្នៃគ្រឿងផ្ទុះ ។

ការកំទេចគ្រឿងផ្ទុះកំរិត៤ត្រូវបញ្ជាក់ច្បាស់ពីជំនាញឯកទេសជាក់លាក់នីមួយៗសំរាប់បុគ្គលម្នាក់ដែលបានធ្វើការហ្វឹកហ្វឺន និងទទួលស្គាល់ជាផ្លូវការ។

**ចំណាំ ១**: គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះខ្លះ មានលក្ខណៈត្រូវទៅតាមជំនាញឯកទេសនៃចំណាត់ថ្នាក់ខាងលើ តែមានការគំរាមជាក់លាក់បន្ថែមទៀត។ ឧទាហរណ៍ដូចជា គ្រាប់រំសេវដែលផ្ទុកហ្វូសហ្វ័រ គ្រាប់មីុស៊ីល

ឬតម្រូវការក្នុងការកំទេចគ្រាប់ជាគំនរធំៗ។ដូចនេះត្រូវធ្វើការហ្វឹកហាត់ជាលក្ខណៈពិសេសទៀតបន្ថែមនូវអ្វីដែលពុំមាននៅក្នុងសមត្ថកិច្ចដូចបានរៀបរាប់ខាងលើ។

**ចំណាំ ២:** ករណីជួបប្រទះគ្រាប់យុទ្ធភ័ណ្ឌពិសេសៗជាញឹកញាប់
ត្រូវមានការបណ្ដុះបណ្ដាលលើការកំទេចគ្រាប់ទាំងនោះបន្ថែម
ដើម្បីអោយអ្នកកំទេចអាចដោះស្រាយបញ្ហានេះបានប្រសើរ
ជាជាងបន្តបញ្ហានេះទៅកំរិតជំនាញឯកទេសខ្ពស់បន្ទាប់ទៀត។

**ចំណាំ ៣:** គួរកត់ចំណាំថា គ្រាប់តូចៗ (កូនគ្រាប់ចេញពីគ្រាប់ទំលាក់) មានគ្រោះថ្នាក់ខ្លាំងក្នុងការកំទេច ដូច្នេះរាល់ការកំទេច ត្រូវធ្វើឡើងដោយបុគ្គលិកដែលមានការបណ្ដុះបណ្ដាល និងទទួលស្គាល់កំរិត៣ ឬ៤ ត្រឹមត្រូវ។

**ចំណាំ ៤:** ការចាត់ថ្នាក់លើអ្នកគ្រប់គ្រង ត្រូវភ្ជាប់ទៅនឹងកំរិតនីមួយៗនៅពេលដែលអ្នកនោះ បានអនុវត្តការងារនៅកំរិតនោះបានយ៉ាងហោចណាស់ក៏ត្រូវមានបទពិសោធន៍ ៣ឆ្នាំ ឬបានហ្វឹកហ្វឺន និងត្រូវបានទទួលស្គាល់ជាផ្លូវការនៅកំរិតខ្ពស់បន្ទាប់។

**ចំណាំ ៥:** ការចាត់ថ្នាក់អ្នកបង្រៀនត្រូវភ្ជាប់ទៅនឹងកំរិតនីមួយៗ នៅពេលដែលអ្នកនោះបានអនុវត្តការងារជាអ្នកគ្រប់គ្រងនៅកំរិតនោះ ហើយបានហ្វឹកហ្វឺនជាផ្លូវការសំរាប់បង្រៀន។

### ២.៣ នីតិវិធីនៃការដោះបន្សាប និងធ្វើអោយមីន/គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានសុវត្ថិភាព

តាមធម្មតាគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវធ្វើការកំទេចនៅនឹងកន្លែងដោយការប្រើឈ្នួកកំទេច។ ក្នុងករណីមិនអាចធ្វើទៅបានដោយបញ្ហាសុវត្ថិភាព ឬបញ្ហាបរិស្ថាននៅក្នុងមូលដ្ឋាន ដូចជាមានអាគារ ឬទីកតាំងផ្សេងៗនៅក្បែរនោះប្រតិបត្តិករដោះមីនត្រូវធ្វើឲ្យគ្រាប់នោះមានសុវត្ថិភាពដោយធ្វើការដោះបន្សាប និង/ឬធ្វើឲ្យអស់អនុភាពផ្ទុះ មុននឹងយកគ្រាប់នោះទៅកន្លែងផ្សេងដើម្បីធ្វើការកំទេច។

ប្រតិបត្តិករដោះមីនដែលមានសមត្ថភាពខាងផ្នែកកំទេចគ្រឿងផ្ទុះ ត្រូវរៀបចំបទដ្ឋាននីតិវិធីប្រតិបត្តិការលំអិតសំរាប់ធ្វើការដោះបន្សាប និងធ្វើឲ្យគ្រាប់អស់អនុភាពផ្ទុះ យោងទៅតាមទំហំគ្រោះថ្នាក់នៃគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនោះ និងស្របទៅតាមការអនុវត្តន៍ការកំទេចគ្រាប់ជាក់ស្ដែងរបស់អន្តរជាតិ។

បើប្រតិបត្តិករដោះមីន មិនមានសមត្ថភាពកំទេចគ្រាប់ដែលបានរកឃើញទេនោះ គេត្រូវដាក់សញ្ញាសំគាល់កំណត់អត្តសញ្ញាណគ្រាប់ និងរាយការណ៍ពីគ្រាប់នោះមកជូនអាជ្ញាធរមីន។ អាជ្ញាធរមីនត្រូវទទួលខុសត្រូវក្នុងការផ្ដល់ការកំទេចគ្រឿងផ្ទុះដ៏សមស្របមួយ សំរាប់ឆ្លើយតបទៅនឹងភារកិច្ចនោះ។ ក្នុងករណីនេះ ក៏អាចស្នើឲ្យប្រតិបត្តិករដោះមីនផ្សេងបំពេញភារកិច្ចនេះបានដែរ។

### ២.៤. នីតិវិធីកំទេច

ប្រតិបត្តិករដោះមីន និង/ឬក្រុមហ៊ុនបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវរៀបចំបទដ្ឋានប្រតិបត្តិការរបស់ខ្លួនសំរាប់ធ្វើការកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ បទដ្ឋាននេះ រួមបញ្ចូលទាំងការកំទេចគ្រាប់នៅនឹងកន្លែង ឬការកំទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលរកឃើញជាគំនរ។ ត្រូវធ្វើការយកចិត្តទុកដាក់ជាពិសេសពីគ្រោះថ្នាក់ដោយសារការសាយភាយបណ្តាលមកពីការផ្ទុះ និងការជះអំបែងស្លែងចេញពីការកំទេច។ ការដ្ឋានដែលត្រូវជ្រើសរើសសំរាប់ធ្វើការកំទេចគ្រាប់ជាគំនរចំនួនច្រើន ត្រូវមានទីតាំងស្ថិតនៅឆ្ងាយពីតំបន់ដែលមានប្រជាជនរស់នៅ ដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ។ ត្រូវចែងក្នុងបទដ្ឋានផងដែរពីការប្រមូលអំបែង ក្នុងករណីដែលកំទេចអំបែងជះពីការកំទេចគ្រឿងផ្ទុះបាចសាចពេញទីកន្លែងកំទេច។ គួរបញ្ចូលការប្រមូល និងការកំទេចគ្រាប់កាំភ្លើងតូចៗដែលរកឃើញក្នុងបទដ្ឋានកំទេចនោះ។

នៅក្នុងបទដ្ឋានប្រតិបត្តិការត្រូវមានចែងលំអិតពីវិធីសាស្ត្រនានាក្នុងការកំទេចដែលប្រតិបត្តិករដោះមីនត្រូវប្រើក្នុងកម្មវិធីរបស់ខ្លួន រួមមានៈ

- ការបំផ្ទុះ
- ការកំទេចដោយចំហេះ (ផ្ទុះកំរិតទាប) រួមទាំងការដុតក្នុងរណ្តៅ និង/ឬ ក្នុងធុង
- នីតិវិធីដោះបន្សាប
- ការកំទេចដោយគ្រាប់បែកឆេះ

ដោយពុំមានករណីលើកលែង ពុំត្រូវដោះបំបែកគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង/ឬ វំសេវផ្ទុះ ដោយបន្សល់កាកសំណល់នៅក្នុងទន្លេ ឬ សមុទ្រនៅកម្ពុជាទេ។

## ២.៥ការដឹកជញ្ជូន ការប្រើប្រាស់ និង ការទុកដាក់គ្រាប់មីន និង គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

នៅពេលដែលគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬ គ្រាប់វំសេវដទៃទៀត (ដែលត្រូវបានធ្វើអោយមានសុវត្ថិភាព) ត្រូវបានចល័តទៅទុក ឬ យកទៅកំទេចជាគំនរ ប្រតិបត្តិករដោះមីនត្រូវអនុវត្តទៅតាមស្តង់ដាសកម្មភាពកំចាត់មីន ជំពូក៤ ស្តីពីការដឹកជញ្ជូន ការប្រើប្រាស់ និង ការទុកដាក់វំសេវផ្ទុះ។

## ៣.កាតព្វកិច្ច និងការទទួលខុសត្រូវ

**៣.១**អាជ្ញាធរមីន ត្រូវ ៖

ក)បង្កើត និង ថែរក្សាស្តង់ដាជាតិស្តីពីនីតិវិធីកំទេចគ្រឿងផ្ទុះ

ខ)បង្កើត និងថែរក្សាស្តង់ដាជាតិសំរាប់កំណត់លក្ខណៈសម្បត្តិរបស់បុគ្គលិកផ្នែកកំទេចគ្រឿងផ្ទុះ

គ)បង្កើត និងថែរក្សាសមត្ថភាពក្នុងការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ដល់ប្រតិបត្តិករដោះមីន និងក្រុមហ៊ុនបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលពាក់ព័ន្ធនៅក្នុងប្រតិបត្តិការកំទេចគ្រឿងផ្ទុះ

ឃ)បង្កើត និងថែរក្សាសមត្ថភាពត្រួតពិនិត្យលើប្រសិទ្ធភាព និងសុវត្ថិភាព នៃប្រតិបត្តិករដោះមីន និងក្រុមហ៊ុនបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ពាក់ព័ន្ធនៅក្នុងប្រតិបត្តិការកំទេចគ្រឿងផ្ទុះ។ ចំនុចនេះពាក់ព័ន្ធផងដែរទៅនឹងការអនុញ្ញាត្តិ លើកំរិតនៃការទទួលស្គាល់លក្ខណៈសម្បត្តិ នៃបុគ្គលិកកំទេចគ្រឿងផ្ទុះ និងសមត្ថភាពនៃការបង្រៀនផ្ទៃក្នុងស្ថាប័ន។

ង)បង្កើតប្រព័ន្ធគ្រប់គ្រងជាតិមួយ សំរាប់ធ្វើរបាយការណ៍អំពីឧប្បទ្ទហេតុកំទេចគ្រឿងផ្ទុះ។

**៣.២ប្រតិបត្តិករដោះមីនត្រូវ ៖**

ក)បង្កើត និងថែរក្សាបទដ្ឋានប្រតិបត្តិការសំរាប់កិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះ ដោយអនុវត្តទៅតាមស្តង់ដាជាតិ និងស្តង់ដាពាក់ព័ន្ធ ព្រមទាំងបទដ្ឋាននានាស្របតាមកាលៈទេសៈជាក់ស្តែង នៅក្នុងមូលដ្ឋាន

ខ)ជ្រើសរើស បណ្តុះបណ្តាល និងបង្កើនសមត្ថភាពបុគ្គលិកអោយបានសមស្រប ដើម្បីអនុវត្តការងារកំទេចគ្រឿងផ្ទុះ

គ)រក្សា និងត្រួតពិនិត្យការហ្វឹកហ្វឺនជំនាញ និងបទពិសោធន៍របស់អ្នកប្រតិបត្តិការងារកំទេចគ្រឿងផ្ទុះ ដោយធានាថាមានតែបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងជំនាញឯកទេសត្រឹមត្រូវប៉ុណ្ណោះ ដែលអនុញ្ញាតឲ្យបំពេញភារកិច្ចនេះ

ឃ)អនុវត្តបទដ្ឋានប្រតិបត្តិការសំរាប់បើកកិច្ចប្រតិបត្តិការកំទេចគ្រឿងផ្ទុះដោយមានប្រសិទ្ធភាព និងសុវត្ថិភាព។

រាជធានីភ្នំពេញ ថ្ងៃទី 20 ខែ[illegible] ឆ្នាំ ២០០៥

**អគ្គលេខាធិការ**

សម សុគ្គា